# ការធ្វើផែនទីធនធានសហគមន៍
# ក្នុងភូមិក្បាលរមាស និងស្រែគរ ក្នុងខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា

សាវតា

ក្នុងខែកក្កដា ឆ្នាំ២០១៤ អង្គការ Mekong Watchដោយមានកិច្ចការជាមួយ 3SPN បានចាប់ផ្តើមជួយភូមិចំនួនពីរ គឺភូមិក្បាលរមាសនិងភូមិស្រែគរ ក្នុងខេត្តស្ទឹងត្រែង ភាគឥសាននៃប្រទេសកម្ពុជា ក្នុងការគូរផែនទីមួយដើម្បីបង្ហាញអំពីធនធានធម្មជាតិដែលពួកគេពឹងផ្អែកទៅលើ។ ភូមិទាំងនេះ កំពុងទទួលរងការប៉ះពាល់ដោយសារទំនប់វារីអគ្គីសនីសេសានក្រោម២ ដែលគេកំពុងសាងសង់នៅលើទន្លេសេសាន ដែលមានចម្ងាយ១,៥គម នៅខ្សែទឹកខាងក្រោមពីទន្លេស្រែពក និងចម្ងាយ២៥គម ពីទីដែលទន្លេទាំងពីរប្រសប់គ្នាជាមួយនឹងទន្លេមេគង្គមេ។

សម្រាប់ព័ត៌មានបន្ថែមអំពីទន្លេសេសានក្រោម២។

http://www.mekongwatch.org/english/country/cambodia/LS2/index.html



៥គីឡូម៉ែត្រពីតំបន់សាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២

អ្នកភូមិជាច្រើន ជាពិសេសអ្នកដែលកំពុងរស់នៅក្នុងភូមិទាំងពីរនេះ បានសម្តែងយ៉ាងច្បាស់ក្រឡែតអំពីក្តីបារម្ភនិងការជំទាស់នឹងគម្រោងនេះ។ យើងសង្ឃឹមថាផែនទីធនធានសហគមន៍នេះអាចជួយឲ្យភូមិទាំងពីរនេះរកឃើញឡើងវិញនូវធនធានធម្មជាតិដ៏សម្បូរបែបដែលពួកគេបានទទួលផល ក៏ដូចជាចំណងដ៏ជិតស្និទ្ធិទៅនឹងប្រវត្តិសាស្ត្រ ប្រពៃណី វប្បធម៌ និងបែបផែនជីវិតរបស់ភូមិទាំងពីរនេះដែរ។ អ្នកភូមិក៏អាចប្រើផែនទីនេះដើម្បីពន្យល់អំពីតម្លៃនៃធនធានធម្មជាតិក្នុងសហគមន៍ដល់អ្នកមកពីខាងក្រៅ ក៏ដូចជាគូបដិបក្ខក្នុងគម្រោងសេសានក្រោម២នេះ ក៏ដូចជាដើម្បីគាំទ្រដល់ការបារម្ភ ការអះអាង និងអារម្មណ៍របស់ពួកគេ ដូចជា «យើងមិនចង់ផ្លាស់ប្តូរទីលំនៅទេ» និង «វប្បធម៌និងប្រពៃណីរបស់យើងមិនអាចផ្លាស់ទៅកន្លែងផ្សេងបានទេ»។ ការតំណាងដែលអាចមើលឃើញ ដូចជាផែនទីនេះ ក៏នឹងជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ការពង្រឹងសិទ្ធិអំណាចរបស់សហគមន៍ ដូចសារតែអ្នកភូមិជាច្រើនជានិគមជនភាគតិច ហើយសមត្ថភាពក្នុងការអានជាភាសាខ្មែរមិនសូវរឹងមាំដែរ។

**តើអ្វីទៅជាគោលបំណងនៃការធ្វើផែនទីនេះ?**

១. ដើម្បីបង្កើនការយល់ដឹងរបស់អ្នកភូមិអំពី៖

- ថាតើធនធានធម្មជាតិអ្វីខ្លះដែលពួកគេមាន

- ថាតើធនធានធម្មជាតិមានសារៈសំខាន់បែបណាសម្រាប់ការរស់នៅរបស់ពួកគេ និង
- ថាតើធនធានធម្មជាតិមានច្រើននិងមានតម្លៃប៉ុណ្ណា

២. ដើម្បីពង្រឹងសមត្ថភាពរបស់អ្នកភូមិក្នុងការរៀបរាប់៖

- អំពីរបៀបដែលពួកគេប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិ
- ថាតើមានបទពិសោធន៍ ប្រវត្តិសាស្ត្រ រឿងរ៉ាវ ព្រឹត្តិការណ៍អ្វីខ្លះ ដែលពួកគេមានជុំវិញធនធានធម្មជាតិទាំងនោះ និង
- ថាតើពួកគេមានការព្រួយបារម្ភនិងមានការប៉ះពាល់យ៉ាងណាដោយសារការបាត់បង់ធនធានធម្មជាតិ ជាពិសេសបាត់បង់ដោយសារតែគម្រោងសេសានក្រោម២នេះ។

**ភូមិទាំងពីរ**




ផែនទីអាងស្តុកទឹកសេសានក្រោម២ និងភូមិសំខាន់ៗនៅក្នុងអាងទន្លេ (វិច្ឆិកា ២០១២)

១. ភូមិក្បាលរមាស

មានទីតាំងនៅតាមទន្លេស្រែពក ហើយនឹងត្រូវលិចលង់ដោយសារតែអាងស្តុកទឹករបស់គម្រោងទន្លេសេសានក្រោម២នេះ។ ភូមិនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦២។ អ្នកភូមិភាគច្រើនជាជនជាតិព្នង។ ប្រពៃណីនិងជីវិតរបស់ពួកគេមានចំណងយ៉ាងរឹងមាំទៅនឹងជំនឿព្រលឹងនិងធនធានធម្មជាតិ។



ភូមិក្បាលរមាស (រូបថតដោយ 3SPN)

២. ភូមិស្រែពក

មានទីតាំងតាមបណ្ដោយទន្លេសេសាន ហើយនឹងត្រូវជន់លិចនៅពេលដែលអាងគម្រោងសេសានក្រោម២ ត្រូវគេបញ្ចូលទឹកបំពេញ។ អ្នកភូមិភាគច្រើនជាជនជាតិឡាវ។ អ្នកភូមិស្រែពកបានផ្លាស់មកនៅលើទីតាំងនេះក្នុងឆ្នាំ ១៩៥៥។



*ការបន់ស្រន់ព្រលឹងក្រហមក នៅភូមិស្រែពក*

**តើការធ្វើផែនទីមានដំណើរការយ៉ាងដូចម្ដេច?**

១. ការបណ្ដុះបណ្ដាលអ្នកសម្របសម្រួល

នៅពេលចាប់ផ្ដើមធ្វើលំហាត់ធ្វើផែនទីនេះ អ្នកសម្របសម្រួលត្រូវបានជ្រើសរើសចេញពីក្នុងចំណោមអ្នកភូមិ។ គេរំពឹងថាអ្នកសម្របសម្រួលត្រូវដឹកនាំសកម្មភាពដោយជំរុញឲ្យមានការចូលរួមពីអ្នកភូមិដទៃទៀត និងដោយព្យាយាមលើកកម្ពស់ការយល់ដឹងអំពីធនធាននៅក្នុងភូមិ។ អ្នកសម្របសម្រួលត្រូវបានប្រាប់ថាមិនឲ្យផ្ដល់ចម្លើយដល់អ្នកភូមិ ប៉ុន្តែ ត្រូវជំរុញឲ្យពួកគេ «គិតនិងដឹងដោយខ្លួនឯង»។

នៅក្បាលរមាស មេដឹកនាំយុវជនម្នាក់ សមាជិកយុវជនបីនាក់ និងមនុស្សចាស់ពីរនាក់ (ប្រុសទាំងអស់) ត្រូវបានជ្រើសរើសធ្វើជាអ្នកសម្របសម្រួល។ ពួកគាត់ត្រូវបានជ្រើសរើសដោយសារតែពួកគាត់មួយចំនួនមានសមត្ថភាពរឹងមាំខាងផ្នែកអាននិងសរសេរ ព្រមទាំងមានចំណេះដឹងអំពីទីតាំងរបស់ធនធានធម្មជាតិ។ នៅថ្ងៃទីមួយនៃការធ្វើផែនទី អ្នកសម្របសម្រួលរៀនចេះដឹងអំពីការគូរផែនទីធនធានដោយខ្លួនឯងសិន ដែលនេះជាផ្នែកមួយនៃការបណ្ដុះបណ្ដាល។



ការបណ្ដុះបណ្ដាលអ្នកសម្របសម្រួលនៅក្បាលរមាស (រូបភាពឆ្វេង ដោយ 3SPN)

## ២. ការគូរផែនទី

១. <u>ការរាយបញ្ជីធនធានធម្មជាតិនៅក្នុងភូមិ</u>

អ្នកសម្របសម្រួលម្នាក់ សួរអ្នកភូមិដែលកំពុងចូលរួមគិតអំពីប្រភេទធនធានធម្មជាតិ ហើយអ្នកសម្របសម្រួលផ្សេងទៀតកត់ត្រាទុកនូវចម្លើយរបស់អ្នកភូមិនៅលើក្រដាសស្អិត។ ដើម្បីឲ្យអ្នកភូមិមានភាពងាយស្រួលក្នុងការឆ្លើយតបនិងដើម្បីធ្វើឲ្យកាន់តែមានភាពច្បាស់លាស់អំពីចំណងរវាងធនធានធម្មជាតិនិងជីវិតប្រចាំថ្ងៃ អ្នកសម្របសម្រួលសួរសំណួរងាយស្រួលឆ្លើយ ដូចជា៖

- តើអ្នកហូបអ្វីកាលពីព្រឹកមិញ?
- (ចង្អុលទៅបាយក្នុងចាន) តើអ្នកបានបាយនេះមកពីណា?
- (ចង្អុលទៅត្រីនៅលើតុ) តើអ្នកបានត្រីនេះមកពីណា?
- ពេលអ្នកដាំបាយធ្វើម្ហូបព្រឹកមិញ តើអ្នកប្រើសម្ភារៈអ្វីខ្លះ?
- តើអ្នកបានអុសមកពីណា?
- តើអ្នកបានថ្នាំងមកពីណា? តើអ្នកបានលុយមកពីណា យកទៅវិញថ្នាំងនោះ?

នៅភូមិស្រែគរ ដើម្បីឲ្យអ្នកភូមិមានអារម្មណ៍កាន់តែស្រួលចិត្ត និងដើម្បីធ្វើឲ្យសកម្មភាពកាន់តែមានភាពរីករាយ ការធ្វើផែនទីត្រូវបង្កើតជាការលេងល្បែងកំសាន្តមួយ ដូចតទៅនេះ៖

រាល់ពេលដែលអ្នកសម្របសម្រួលសួរសំណួរណាមួយ អ្នកសម្របសម្រួលត្រូវបោះបាល់ទៅអ្នកភូមិម្នាក់។ អ្នកភូមិណាដែលបានទទួលបាល់ត្រូវតែឆ្លើយសំណួរនោះ។ អ្នកសម្របសម្រួលម្នាក់ផ្សេងទៀតសរសេរចម្លើយរបស់អ្នកភូមិនៅលើក្រដាសស្អិត។





ការធ្វើផែនទីនៅស្រែគរ

## ២. ការដាក់បិតធនធានធម្មជាតិទៅលើផែនទីទទេរមួយ

បន្ទាប់ពីអ្នកភូមិបានគិតឃើញដល់ធនធានធម្មជាតិទាំងឡាយនិងត្រូវបានសរសេរនៅលើក្រដាសស្អិត និង ដាក់នៅលើក្រដាសផ្ទាំងធំរួចហើយ ការគូរផែនទីចាប់ផ្តើម។

ដំបូង អ្នកសម្របសម្រួលសរសេរអំពីទីតាំងសំខាន់ៗនៅក្នុងភូមិ ដូចជាទន្លេ នៅលើផ្ទាំងក្រដាសទទេរមួយ។ បន្ទាប់មក អ្នកសម្របសម្រួលម្នាក់យកក្រដាសស្អិតមួយបិតពីលើ ហើយកាន់វាលើកឡើងឲ្យខ្ពស់ ឲ្យអ្នកចូលរួមទាំងអស់មើលឃើញ ហើយសួរទៅអ្នកចូលរួមដូចជា សួរថា «តើអ្នករកឃើញបឹងព្រៃកប៉ូងកនៅកន្លែងណា?»។ អ្នកភូមិឆ្លើយតប ដោយចង្អុលទៅទិសនៃបឹងនោះថា «នៅទីនេះ។ នៅក្រោយភូមិរបស់យើង»។ បន្ទាប់មក អ្នកសម្របសម្រួលដាក់ក្រដាសស្អិតនោះនៅលើផែនទីទទេរនោះតាមទីតាំងសមស្រប។

អ្នកសម្របសម្រួលនិយាយម្តងហើយម្តងទៀតអំពីសំណួរនិងចម្លើយ រហូតទាល់តែក្រដាសស្អិតទាំងអស់នោះផ្ទេរទៅលើផែនទី។ មនុស្សចាស់ដែលដឹងច្រើនអំពីភូមិនេះ ជាពិសេសអំពីទីតាំងនៃធនធានធម្មជាតិទាំងនោះ ជួយដល់ដំណើរការនេះច្រើនណាស់ ខណៈពេលដែលស្ត្រីឬក្មេងៗដែលមិនដែលបានឃើញឬមិនដែលបានទៅដល់កន្លែងដែលនៅឆ្ងាយពីភូមិ បានរៀនចេះដឹងពីមនុស្សចាស់ទាំងឡាយអំពីធនធានធម្មជាតិដែលអាចរកបាននិងនៅកន្លែងណា។



ផែនទីទទេរមួយ ដោយមានទន្លេជាទីតាំងសំខាន់ (នៅក្បាលរមាស) (រូបថតដោយ 3SPN)





ការផ្ទេរក្រដាសស្អិតទាំងអស់ទៅលើផែនទីទទេរ(នៅក្បាលរមាស)(រូបថតខាងក្រោម ដោយអ្នកសម្របសម្រួលពីក្រុមយុវជន)

## ៣. ការគូររូបនៅលើផែនទី

បន្ទាប់ពីបានផ្ទេរក្រដាសស្អិតទាំងអស់ទៅលើផែនទីហើយ គេឲ្យអ្នកភូមិគូររូបធនធានធម្មជាតិនិមួយៗ។ ដើម្បីឲ្យអ្នកភូមិដែលមិនសូវចេះអក្សរបានចូលរួម អ្នកសម្របសម្រួលចែកប៊ិចនិងខ្មៅដៃដែលមានពណ៌ផ្សេងគ្នាដល់ពួកគាត់។ អ្នកភូមិត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការពិភាក្សានិងយល់ស្របគ្នាអំពីប្រភេទនៃរូបភាពដែលសមស្របជាមួយនឹងពណ៌ ដើម្បីឲ្យទាំងអស់គ្នាក្នុងភូមិអាចសម្គាល់បានថាជាអ្វី។ បន្ទាប់មក ពួកគេគូររូបភាពមួយនៅជិត

ក្រដាសស្អិតនិមួយៗនៅលើផែនទី។

គ្រប់ពេលដែលមាននរណាគូររូបមួយរួចរាល់ហើយ ក្រដាសស្អិតនៅជាប់រូបនោះត្រូវដកយកចេញ រហូតដល់អ្នកភូមិបញ្ចប់ការគូររូបធនធានធម្មជាតិទាំងអស់ដែលមាននៅលើផែនទីនោះ។ ផែនទីធនធានធម្មជាតិសហគមន៍ ត្រូវបានធ្វើចប់រួចរាល់។



អ្នកភូមិកំពុងគូររូបនៅលើផែនទី (នៅក្បាលមោស) (រូបថតដោយអ្នកសម្របសម្រួលពីក្រុមយុវជន)



អ្នកភូមិកំពុងគូររូបនៅលើផែនទី (នៅស្រែគរ)



ផែនទីបង្កើតឡើងដោយអ្នកភូមិក្បាលមោស



ផែនទីបង្កើតឡើងដោយអ្នកភូមិស្រែគរ

### ៣. ការថតរូបធនធានធម្មជាតិ

ដើម្បីធ្វើឲ្យអ្នកភូមិកាន់តែងាយស្រួលសម្គាល់ធនធានធម្មជាតិនៅលើផែនទី អ្នកសម្របសម្រួលចេញទៅក្រៅ ដើម្បីមើលទីតាំងនៃធនធានធម្មជាតិសំខាន់ៗនៅក្នុងភូមិ និងថតរូបដើម្បីបង្ហាញដល់អ្នកភូមិ។

មុនពេលចេញទៅក្រៅ អ្នកភូមិមួយចំនួនត្រូវរៀនឲ្យចេះរបៀបប្រើម៉ាស៊ីនថត។ បន្ទាប់មក អ្នកភូមិត្រូវបែងចែកជាក្រុមតូចៗ។ ក្រុមនិមួយៗ យ៉ាងហោចណាស់មានអ្នកភូមិម្នាក់ដែលដឹងច្រើនអំពីទីតាំងធនធានធម្មជាតិ និងម្នាក់ទៀតមកពីក្រុមយុវជន ដែលចេះប្រើម៉ាស៊ីនថត។ ចេតនាមួយនៅពីក្រោយការងារនេះ គឺការជំរុញឲ្យសមាជិកជាយុវជនបានទៅឃើញធនធានធម្មជាតិដែលពួកគេមិនដែលបានឃើញឬមិនដែលបានទៅដល់។



សមាជិកក្រុមយុវជនម្នាក់កំពុងថតរូបវាលស្រែ (នៅក្បាលរមាស)



ក្រុមមួយចេញទៅក្នុងព្រៃដើម្បីថតរូប និងជួបជាមួយអ្នកភូមិម្នាក់ដែលរស់នៅជិតនោះ។ អ្នកភូមិនោះ នាំផ្លូវក្រុមនេះចូលទៅក្នុងព្រៃ។

ដោយសារតែភូមិក្បាលរមាសមានទំហំធំ អ្នកភូមិចំណាយពេលពេញមួយថ្ងៃដោយថតបានរូបមិនបានដល់ពាក់កណ្តាលនៃទីតាំងទាំងឡាយដែលគេបានដាក់នៅលើផែនទីផង។ រូបថតទាំងអស់ត្រូវបានផ្តិតនៅលើក្រដាសស្អិតតូចៗ ដើម្បីឲ្យអ្នកភូមិអាចបិតបន្ថែមទៅលើផែនទីធនធាននោះបានដោយងាយស្រួល។

#### តើអ្នកភូមិប្រើផែនទីយ៉ាងដូចម្តេច?

ក្នុងខែសីហា អង្គការ Mekong Watch និង 3SPN ជួយរៀបចំសិក្ខាសាលាមួយមួយនៅភូមិក្បាលរមាសដើម្បីបង្ហាញផែនទីពេញលេញ ទៅដល់អ្នកភូមិឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

នៅពេលចាប់ផ្ដើមការប្រជុំ អ្នកសម្របសម្រួលម្នាក់ពន្យល់ថា ផែនទីនោះអាចបង្ហាញអំពីធនធានធម្មជាតិនិងទីតាំងរបស់ធនធានធម្មជាតិនៅក្នុងភូមិ ព្រមទាំងនិយាយថា «ខ្ញុំស្គាល់ភ្នំរឿង ហើយមានធនធានជាច្រើននៅទីនោះ ប៉ុន្តែខ្ញុំមិនដឹងច្រើនអំពីប្រភេទធនធានទាំងនោះទេ ហើយយើងបានប្រើធនធានទាំងនោះយ៉ាងដូចម្ដេចនោះទេ។ នៅពេលដែលមានអ្នកមកពីក្រៅហើយសួរយើងអំពីភូមិរបស់យើង យើងគ្រប់គ្នាគួរមានលទ្ធភាពឆ្លើយនិងពន្យល់អំពីធនធានធម្មជាតិទាំងអស់នេះបាន»។

នៅថ្ងៃនោះ បុរសបីនាក់និងស្ត្រីពីរនាក់បានស្ម័គ្រចិត្តដាក់វេនគ្នាមកឈរនៅពីមុខផែនទី និងចែករំលែកចំណេះដឹងរបស់ពួកគេអំពីកន្លែងនិមួយៗនៅលើផែនទី ឧទាហរណ៍ ឈ្មោះកន្លែង ហេតុអ្វីបានជាគេដាក់ឈ្មោះបែបនោះ តើភូមិបានប្រើប្រាស់ធនធានធម្មជាតិនៅជុំវិញកន្លែងនិមួយៗយ៉ាងដូចម្ដេច ហើយតើបច្ចុប្បន្ននេះមានការផ្លាស់ប្ដូរអ្វីខ្លះ ជាដើម។


បទបង្ហាញ

**តើអ្នកភូមិយល់យ៉ាងដូចម្ដេចចំពោះផែនទីនោះ?**

<u>រិទ្ធី, អ្នកសម្របសម្រួលពីក្រុមយុវជននៅក្បាលរមាស</u>



*«នៅថ្ងៃដែលខ្ញុំថតរូបនៅកន្លែងផ្សេងៗនៅក្នុងភូមិរបស់យើងនោះ ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ដែលបានដឹងអំពីទីកន្លែងនិងប្រភេទធនធានធម្មជាតិដែលយើងមាននៅក្នុងភូមិ។ ខ្ញុំកាន់តែមានឆន្ទៈក្នុងការស្នើសុំឲ្យអ្នកភូមិផ្សេងទៀតការពារទីតាំងទាំងឡាយដែលខ្ញុំបានថតនិងកត់ត្រាដាក់នៅលើផែនទីសហគមន៍។»*

*«ខ្ញុំគិតថាការធ្វើផែនទីនេះមានសារៈសំខាន់ណាស់សម្រាប់ពួកយើង។ សមាជិកសហគមន៍អាចយល់អំពីសារៈសំខាន់របស់ធនធានធម្មជាតិនិងកន្លែងដែលតាំងនៅ។ ពួកគេកាន់តែងាយស្រួលសម្គាល់អំពីសារៈសំខាន់អំពីធនធានទាំងនោះចំពោះជីវិតរបស់យើង។ ខ្ញុំសូមសំណូមពរឲ្យភូមិដទៃទៀតដែលមិនទាន់បានធ្វើផែនទីសហគមន៍នៅឡើយនោះថា ពួកគេគួរតែចូលរួមជាមួយយើង និងត្រូវធ្វើផែនទីសម្រាប់ភូមិសហគមន៍របស់ពួកគេដែរ»។*

យ៉ែម ចាន់នី, សមាជិកក្រុមយុវជននៅក្បាលរមាស

*«ផែនទីនេះ មានប្រយោជន៍ខ្លាំងណាស់ ពីព្រោះយើងអាចចេះដឹងបន្ថែមអំពីកន្លែងដែលយើងរស់នៅក្នុងពេលបច្ចុប្បន្ននេះ អំពីកន្លែងដែលយើងមិនធ្លាប់បានទៅ ក៏ដូចជាកន្លែងរបស់យើង»។*

ដាំ បាង, អ្នកភូមិក្បាលរមាស



*«សហគមន៍របស់យើងធ្វើការរួមគ្នាដើម្បីធ្វើផែនទីនេះ។ ខ្ញុំគិតថាការធ្វើផែនទីសហគមន៍នេះមានប្រយោជន៍ណាស់ចំពោះយើង។ សូម្បីតែក្រោយពេលដែលយើងរើទៅនៅកន្លែងផ្សេងក៏ដោយ ក៏យើងនៅតែអាចប្រើផែនទីនេះដើម្បីបង្ហាញដល់អ្នកដទៃអំពីទំហំដីដែលយើងមាន។ ក្រុមហ៊ុនបានប្រាប់យើងថា ដីនេះនឹងត្រូវគេយក (សម្រាប់ធ្វើទំនប់សេសានក្រោម២) ហើយជាការផ្លាស់ប្តូរ យើងនឹងត្រូវរើទៅរស់នៅកន្លែងថ្មីមួយ។ ខ្ញុំសុខចិត្តរស់នៅលើដីទួលនៅទីនេះ ជាងរស់នៅក្នុងភូមិថ្មី ពីព្រោះប្រសិនបើយើងរើទៅភូមិថ្មី យើងនឹងបាត់បង់ប្រពៃណីនិងផ្នូររបស់ដូនតាយើង»។*

សម្គាល់៖ គ្រប់រូបភាពទាំងអស់នៅលើទំព័រនេះ ថតដោយអង្គការ Mekong Watch ក្នុងឆ្នាំ២០១៤ ប្រសិនបើមិនមានការបញ្ជាក់ផ្សេងពីនេះ។

ធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤